វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA
STRENGTHENING PARLIAMENTARY CAPACITY

# ព្រឹត្តប័ត្រព័ត៌មានសង្ខេប

**សប្តាហ៍ដែលបញ្ចប់**
**ថ្ងៃទី២៨ ខែមិថុនា ២០១៩**

ចំណុចសំខាន់ៗ អំពីព័ត៌មានសេដ្ឋកិច្ច និងការអភិវឌ្ឍសារពើពន្ធនៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន និងនៅប្រទេសផ្សេងៗទៀតនៅក្នុងសប្តាហ៍នេះគឺ៖

- សន្និសីទប្រចាំឆ្នាំអំពីម៉ាក្រូសេដ្ឋកិច្ចរបស់ធនាគារជាតិ នឹងលើកពីប្រធានបទដែលទាក់ទងនឹង កសិកម្ម
- ប្រទេសវៀតណាមឆ្ពោះទៅរកការធ្វើអោយស្របច្បាប់នៃឧស្សាហកម្មព្រៃឈើ និងបង្កើនកិច្ចសហការជាមួយសហរដ្ឋអាមេរិក
- ធនាគារកណ្តាលអាមេរិកនឹងត្រួតពិនិត្យកាក់ឌីជីថលរបស់ហ្វេសប៊ុក

*ព្រឹត្តប័ត្រសង្ខេបព័ត៌មាននេះ គឺជាព្រឹត្តិប័ត្រប្រចាំសប្តាហ៍ដែលរៀបចំឡើងដើម្បីតាមដានព័ត៌មានអំពីការអភិវឌ្ឍសេដ្ឋកិច្ច និងសារពើពន្ធថ្មីៗនៅក្នុងប្រទេសកម្ពុជា និងដៃគូពាណិជ្ជកម្មនានា។ ឯកសារនេះត្រូវបានធ្វើឡើងដោយក្រុមការងារបណ្តុះបណ្តាលសមត្ថភាពការវិភាគសារពើពន្ធរបស់វិទ្យាស្ថានសភាកម្ពុជា ក្នុងគោលបំណងពង្រឹងជំនាញនៃការធ្វើឯកសារ និងការស្រាវជ្រាវរបស់ខ្លួន។ ការងារនេះត្រូវបានព្យាយាមធ្វើឡើងដើម្បីធានាថាការវិភាគ និងអត្ថន័យ ដែលបានផ្តល់នៅក្នុងឯកសារនេះ មានគុណភាពខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ សូមអ្នកអានចាត់ទុកឯកសារនេះជាផ្នែកមួយនៃលំហាត់អនុវត្តនៅក្នុងកំឡុងពេលនៃការបណ្តុះបណ្តាល។ យើងមិនអាចធានាថាឯកសារនេះល្អឥតខ្ចោះនោះទេ។*

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### សន្និសីទប្រចាំឆ្នាំអំពីម៉ាក្រូសេដ្ឋកិច្ចរបស់ធនាគារជាតិ នឹងលើកពីប្រធានបទដែលទាក់ទងនឹងកសិកម្ម

យោងតាមកាសែតភ្នំពេញប៉ុស្តិ៍ ធនាគារជាតិនៃកម្ពុជានឹងរៀបចំសន្និសីទប្រចាំឆ្នាំស្តីពីម៉ាក្រូសេដ្ឋកិច្ចនៅចុងឆ្នាំ២០១៩នេះ ដោយផ្តោតលើប្រធានបទបញ្ហាប្រឈមនៅក្នុងវិស័យកសិកម្ម។ ទោះបីជាវិស័យកាត់ដេរ វិស័យទេសចរណ៍ និងវិស័យសំណង់មានការកើនឡើងយ៉ាងខ្លាំងក៏ដោយ ក៏វិស័យកសិកម្មនៅតែចូលរួមចំណែកដ៏សំខាន់ដល់កំណើនសេដ្ឋកិច្ចជាតិ។

ធនាគារជាតិនៃកម្ពុជាបានធ្វើការកត់សម្គាល់ថា បញ្ហាប្រឈមសំខាន់ៗនៅក្នុងវិស័យកសិកម្មគឺកង្វះខាតកម្លាំងពលកម្មនៅតាមទីជនបទ និងកង្វះខាតផ្នែកហេដ្ឋារចនាសម្ព័ន្ធ។ កង្វះខាតកម្លាំងពលកម្មប្រហែលអាចជាបញ្ហាកាន់តែរីកធំ ដោយសារតែការហូរចេញនូវកម្លាំងពលកម្មជនបទ ទៅប្រទេសជិតខាង ដែលជាក់ស្តែងប្រជាពលរដ្ឋខ្មែរប្រមាណជា ១,១ លាននាក់បានធ្វើចំណាកស្រុកទៅក្រៅប្រទេស ដែលមួយភាគធំគឺនៅប្រទេសថៃ។

ការលុបចោលការលើកលែងពន្ធលើគម្រោងនាំចេញអង្ករទៅកាន់សហភាពអឺរ៉ុប អាចនឹងនាំអោយប៉ះពាល់ដល់សុខមាលភាពរបស់ប្រជាកសិករ ប៉ុន្តែផ្ទុយមកវិញ សង្គ្រាមពាណិជ្ជកម្មរវាង ចិន និង អាមេរិក អាចនឹងបង្កើតឱកាសប៉ះប៉ូវដល់កម្ពុជាវិញ។

### តារាងប្រចាំសប្តាហ៍៖ ចំណូលក្នុងប្រទេសសរុបប្រចាំត្រីមាសទី១ ពីឆ្នាំ២០១៦-២០១៩

តារាងប្រចាំសប្តាហ៍នេះបង្ហាញពីកម្រិត និងអត្រាកំណើនចំណូលក្នុងប្រទេសសរុបប្រចាំត្រីមាសទី១ ក្នុងឆ្នាំ២០១៩ និង៣ឆ្នាំមុន។ បន្ទាប់ពីកំណើនថមថយក្នុងឆ្នាំ២០១៨ ទិន្នន័យដំបូងនៅក្នុងឆ្នាំ

២០១៩ បានបង្ហាញអោយឃើញថា ចំណូលក្នុងប្រទេសសរុបក្នុងត្រីមាសទី១ មានការកើនឡើងវិញ ពោលគឺមានកំណើនពីរខ្ទង់។

**ចំណូលក្នុងប្រទេសសរុបប្រចាំត្រីមាសទី១ ពីឆ្នាំ២០១៦-២០១៩**




ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (TOFE 2015-2019)

# ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

## ប្រទេសវៀតណាមឆ្ពោះទៅរកការធ្វើអោយស្របច្បាប់នៃឧស្សាហកម្មព្រៃឈើ និងបង្កើនកិច្ចសហការជាមួយសហរដ្ឋអាមេរិក

ប្រទេសវៀតណាមបាននឹងកំពុង ខិតខំបង្កើនស្ថិរភាព និងភាពស្របច្បាប់នៃឧស្សាហកម្មកែច្នៃឈើរបស់ខ្លួន ដោយផ្តេកទៅលើច្បាប់អន្តរជាតិដើម្បីបញ្ជ្រាបការនាំចេញទៅកាន់ទីផ្សារសំខាន់ៗ ដូចជា៖ សហរដ្ឋអាមេរិក សហភាពអឺរ៉ុប និងប្រទេសជប៉ុន។

យោងតាមអនុប្រធានសមាគមផលិតផលឈើ និងព្រៃឈើវៀតណាម ការនាំចេញឈើ និងផលិតផលព្រៃឈើមានទំហំ ៩,៤ ប៊ីលានដុល្លារ កាលពីឆ្នាំទៅ ដែលក្នុងនោះប្រហែលជា ៤២%បាននាំចេញទៅកាន់ អាមេរិក។

នៅក្នុងឆ្នាំនេះ រដ្ឋាភិបាលវៀតណាមបានធ្វើផែនការនាំចេញវិស័យផលិតផលព្រៃឈើរហូតដល់ទៅ ១១ប៊ីលានដុល្លារ។ ដើម្បីសម្រេចផែនការនេះ រដ្ឋាភិបាលបានធ្វើការប្តេជ្ញាចិត្តធ្វើការវិនិយោគក្រោមលក្ខខណ្ឌមួយចំនួន ដើម្បីធ្វើអោយបរិយាកាសអាជីវកម្មព្រៃឈើរយៈពេលខ្លីមានភាពល្អប្រសើរ ខណៈដែលធ្វើការវិនិយោគផងដែរសម្រាប់រយៈពេលវែងប្រកបដោយចីរភាព និងការដាំដើមឈើឡើងវិញ ដើម្បីរក្សាប្រាក់ចំណូល អោយមានស្ថិរភាពសម្រាប់ប្រជាជនជំនាន់ក្រោយ។

# សេដ្ឋកិច្ចពិភពលោក

## ធនាគារកណ្តាលអាមេរិក នឹងត្រួតពិនិត្យកាក់ឌីជីថលរបស់ហ្វេសប៊ុក

លោក Jerome Powell ប្រធានធនាគារកណ្តាលអាមេរិកបាននិយាយកាលពីថ្ងៃអង្គារថាធនាគារកណ្តាលនឹងត្រួតពិនិត្យរូបិយប័ណ្ណឌីជីថល ដែលបានប្រកាសកាលពីសប្តាហ៍មុនដោយក្រុមហ៊ុនហ្វេសប៊ុក ទៅកាន់ដៃគូរបស់ខ្លួន។ រូបិយប័ណ្ណថ្មីរបស់ហ្វេសប៊ុកដែលហៅថា លីប្រា(Libra) មានគោលបំណងកាត់បន្ថយថ្លៃប្រតិបត្តិការ និងនាំមកនូវសេវាកម្មបន្ថែមនានាដល់អ្នកដែលមិនមានលទ្ធភាពប្រើប្រាស់សេវាធនាគារ។

ធនាគារកណ្តាលកំពុងរង់ចាំព័ត៌មានបន្ថែម ពីរូបិយប័ណ្ណលីប្រា (Libra) ដែលរក្សាទ្រព្យសកម្មបម្រុងនៅទីក្រុងហ្សឺណែវ សម្រាប់រក្សាស្ថិរភាពតម្លៃរូបិយប័ណ្ណរបស់ខ្លួន ដោយពិនិត្យមើលលើការពាក់ព័ន្ធបទប្បញ្ញត្តិនានាដែលមានសក្តានុពលនាពេលអនាគត។

# ព័ត៌មានសម្រាប់សប្តាហ៍បន្ទាប់

ទិន្នន័យសំខាន់ៗនៅក្នុងសប្តាហ៍ខាងមុខនេះរួមមាន ស្ថិតិអតិផរណាសម្រាប់ខែមិថុនានៅក្នុងប្រទេសឥណ្ឌូណេស៊ី កូរ៉េខាងត្បូង ហ្វីលីពីន និងតៃវ៉ាន់ និងការសម្រេចចិត្តអត្រាការប្រាក់ដោយធនាគារអូស្ត្រាលី។

ខាងក្រោមគឺជាប្រតិទិនពេញលេញនៃការចេញនូវទិន្នន័យ និងការអភិវឌ្ឍ ដែលក្រុម FACT នឹងបន្តតាមដាននៅសប្តាហ៍ក្រោយ៖

ថ្ងៃច័ន្ទ ទី០១ ខែកក្កដា

- តុល្យភាពពាណិជ្ជកម្មនៅកូរ៉េខាងត្បូង សម្រាប់ខែមិថុនា
- អតិផរណាប្រទេសឥណ្ឌូណេស៊ី សម្រាប់ខែមិថុនា
- ការមកដល់ភ្ញៀវទេសចរណ៍ឥណ្ឌូណេស៊ីសម្រាប់ខែឧសភា
- ទំនុកចិត្តអ្នកប្រើប្រាស់របស់ជប៉ុន នៅខែមិថុនា
- កំណើនប្រាក់កម្ចីតំបន់អឺរ៉ុប សម្រាប់ខែឧសភា

ថ្ងៃអង្គារ ទី០២ ខែកក្កដា

- ការសម្រេចចិត្តអត្រាការប្រាក់របស់ធនាគារអូស្រ្តាលី (RBA)
- តុល្យភាពថវិការបស់បារាំង សម្រាប់ខែឧសភា
- តម្លៃផ្ទះនៅទូទាំង ចក្រភពអង់គ្លេសសម្រាប់ខែមិថុនា
- តម្លៃលក់រាយនៅហ្វីលីពីន សម្រាប់ខែឧសភា
- ទំនុកចិត្តអាជីវកម្មនៅថៃ សម្រាប់ខែមិថុនា
- អតិផរណារបស់កូរ៉េខាងត្បូង សម្រាប់ខែមិថុនា

ថ្ងៃពុធ ទី០៣ ខែកក្កដា

- តុល្យភាពពាណិជ្ជកម្ម អូស្រ្តាលីសម្រាប់ខែឧសភា
- តុល្យភាពពាណិជ្ជកម្ម អាមេរិកសម្រាប់ខែឧសភា
- សន្ទរកថារបស់លោក Funo ធនាគារប្រទេសជប៉ុន
- សន្ទស្សន៍ការបញ្ជាទិញ ក្នុងទីផ្សារប្រទេសសឹង្ហបុរី សម្រាប់ខែមិថុនា

ថ្ងៃព្រហស្បតិ៍ ទី០៤ ខែកក្កដា

- ការលក់រាយតំបន់អឺរ៉ុប សម្រាប់ខែឧសភា
- ការលក់រាយនៅ បារាំងសម្រាប់ខែឧសភា
- គណនីចរន្តរបស់ កូរ៉េខាងត្បូងសម្រាប់ខែឧសភា
- តុល្យភាពពាណិជ្ជកម្មនៅ ម៉ាឡេស៊ីសម្រាប់ខែឧសភា
- ទំនុកចិត្តអ្នកប្រើប្រាស់ នៅថៃនៅខែមិថុនា

ថ្ងៃសុក្រ ទី០៥ ខែកក្កដា

- អតិផរណានៅ ហ្វីលីពីន សម្រាប់ខែមិថុនា
- ផលិតកម្មឧស្សាហកម្មនៅហ្វីលីពីន សម្រាប់ខែឧសភា
- ទុនបំរុងរូបិយប័ណ្ណបរទេសរបស់ថៃ សម្រាប់ខែមិថុនា
- អតិផរណាតៃវ៉ាន់ សម្រាប់ខែមិថុនា